នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jul-2012, 10:51
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ ឧបសម្ព័ន្ធសម្ងាត់ និងឧបសម្ព័ន្ធសាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III, និងឧបសម្ព័ន្ធ IV សាធារណៈ

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | | លោក សុន អរុណ |
| | | លោក Michiel PESTMAN |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ** | លោក Victor Koppe |
| | លោក អាង ឧត្តម |
| ពេជ អង្គ | លោក Michael G.KARNAVAS |
| Elisabeth SIMONNEAU FORT | លោក គង់ សំអុន |
| | Anta GUISSÉ |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១- កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួន សុំឲ្យទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី១ (ញត្តិស្នើសុំសម្រាប់ដំណាក់កាលទីមួយ)[1]។ នៅក្នុងញត្តិស្នើសុំសម្រាប់ដំណាក់កាលទីមួយ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ថា សហព្រះរាជអាជ្ញានឹងដាក់ញត្តិស្រដៀងគ្នានេះ ក្នុងរយៈពេលដ៏ខ្លីខាងមុខ ដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២[2]។

២- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានចេញ *សេចក្តីសម្រេចរបស់ខ្លួនលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (“សេចក្តីសម្រេច”)*[3] ។ សេចក្តីសម្រេចនេះបានអនុញ្ញាតឲ្យភាគីដាក់ជូនអង្គជំនុំជម្រះនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹករបស់បុគ្គលដែលបច្ចុប្បន្នមិនត្រូវបានកំណត់ពេលឲ្យចូលបង្ហាញខ្លួនជាសាក្សី និងបានគូសបញ្ជាក់ជាទូទៅពីកត្តាផ្សេងៗដែលនឹងត្រូវលើកយកមកពិចារណាដោយអង្គជំនុំជម្រះនៅក្នុងការកំណត់អំពីភាពអាចទទួលយកបាន និងតម្លៃភវនីយភាពនៃឯកសារដែលបានផ្តល់ជូន ដើម្បីបញ្ជាក់លើបញ្ហាផ្សេងៗ ក្រៅពីសកម្មភាព និងអំពើរបស់ជនជាប់ចោទ[4]។

៣- ដូចដែលបានជម្រាបឲ្យដឹងជាមុនរួចហើយនៅក្នុងញត្តិស្នើសុំសម្រាប់ដំណាក់កាលទីមួយ និងចម្លើយតបជាផ្នែកៗចំពោះសេចក្តីសម្រេចនេះ សហព្រះរាជអាជ្ញាដាក់ញត្តិមួយនាពេលនេះ និងអមដោយឧបសម្ព័ន្ធចំនួនបួនមកជាមួយ ទាក់ទងទៅនឹងចម្លើយសាក្សីនានាដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ និងបញ្ហាភស្តុតាងផ្សេងៗទៀត។ ជាងនេះទៀត ទោះបីជាញត្តិដំណាក់កាលទីមួយនេះ បានដាក់ជូនមុនសេចក្តីសម្រេចក៏ដោយ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលា

---

[1] ឯកសារលេខ E208 សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២

[2] ក្នុងឯកសារលេខ E208 ដដែលដូចខាងលើ, កថាខណ្ឌទី៥។

[3] **E96/7** *សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*, ២០ មិថុនា ២០១២។

[4] ក្នុងឯកសារលេខ **E96/7** ដដែលដូចខាងលើ, កថាខណ្ឌទី២៣-២៥។

ដំបូងពិចារណាញត្តិដំណាក់កាលទីមួយ និងឧបសម្ពន្ធភ្ជាប់ ដែលជាប់ជាមួយញត្តិភ្លាមៗនេះ អនុវត្តទៅតាមលក្ខណៈវិនិច្ឆ័យ និងទម្រង់បែបបទនៃសេចក្តីសម្រេចនេះ ជាផ្នែកមួយនៃចម្លើយតបនេះដែលមាននៅក្នុងញត្តិនោះដែរ។

៤- ចម្លើយជាលាយលក្ខណ៍អក្សរដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងញត្តិស្នើសុំលើកទីមួយ និងញត្តិស្នើសុំភ្លាមៗ "ដែលឈានទៅធ្វើជាភ័ស្តុតាងអំពីបញ្ហានានា ក្រៅពីសកម្មភាព ឬអំពើរបស់ជនជាប់ចោទ (និង..*ដែលគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* មានភាពជាប់ទាក់ទង និងអាចឱ្យជឿទុកចិត្តបាន ហើយម្យ៉ាងទៀតមិនត្រូវបានដកចេញពីលក្ខណៈវិនិច្ឆ័យក្រោមវិធាន៨៧(៣)នោះឡើយ"[5]។ ជាលទ្ធផល ចម្លើយជាលាយលក្ខណ៍អក្សរទាំងនេះគឺ "អាចឱ្យទួលយកបាន...ដោយមិនចាំបាច់តម្រូវឱ្យមានការចូលរួមពី [អ្នកនិពន្ធ] នៅក្នុងសវនាការនោះឡើយ" ហើយ [អង្គជំនុំជម្រះ] ដោយផ្អែកលើលក្ខខណ្ឌមួយអាចពឹងផ្អែកលើឯកសារនោះ"[6]។ ដូចដែលមានការពន្យល់បន្ថែមខាងក្រោមនេះ និងនៅក្នុងញត្តិស្នើសុំលើកទីមួយ មូលហេតុដែលនាំឱ្យចម្លើយទាំងនេះមានភវនីយភាពខ្ពស់គឺរួមមានហេតុផលថា ចម្លើយទាំងនេះ "មានភាពត្រួតគ្នា" ដែលមានភាពស៊ីសង្វាក់គ្នា "ទាក់ទងទៅនឹងប្រវត្តិសាស្ត្រនយោបាយ និងយោធាដែលមានការពាក់ព័ន្ធ, ដែលទាក់ទងនឹងភ័ស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្ម..ដែលឈានទៅដល់ការបង្ហាញភ័ស្តុតាងអំពីធាតុផ្សំបទល្មើសក្នុងឧក្រិដ្ឋកម្មអន្តរជាតិ និងពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មផ្សេងៗទៅលើជនរងគ្រោះ"[7]។

៥- បន្ថែមលើនេះ ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធនានាភ្ជាប់ទៅនឹងញត្តិដំណាក់កាលទីមួយ និងញត្តិភ្លាមៗ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត("កសចស")។ "កំណត់ហេតុដែលធ្វើឡើងក្នុងអំឡុងកិច្ចស៊ើបសួរ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពជឿជាក់បាន"[8]។ ដោយគិតដល់ការសន្មតទុកជាមុននេះ និងដោយយោងទៅតាម

---

[5] ឯកសារលេខ **E96/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* កថាខណ្ឌទី២៣ ។ លើសពីនេះ តាមកម្រិតដែលព័ត៌មានណាមួយដែលមាននៅក្នុងចម្លើយនានាដែលត្រូវបានបកស្រាយដោយអង្គជំនុំជម្រះថាមានការជាប់ទាក់ទងទៅនឹងសកម្មភាព ឬអំពើរបស់ជនជាប់ចោទនោះ សហព្រះរាជអាជ្ញាមិនព្រមទទួលស្គាល់អំពីគោលបំណងដែលចង់ប្រើប្រាស់នូវចម្លើយទាំងនេះសម្រាប់គោលបំណងនាពេលបច្ចុប្បន្ននេះឡើយ។

[6] ឯកសារលេខ **E96/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* កថាខណ្ឌទី២៣ ។.

[7] ឯកសារលេខ **E96/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* កថាខណ្ឌទី២៤ ។

[8] **E96/7** *ក្នុងឯកសារដដែលដូចខាងលើ,* កថាខណ្ឌទី២៦។

កត្តានានាដែលអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណ សហព្រះរាជអាជ្ញាសន្និដ្ឋានថាកំណត់ហេតុទាំងនេះកំណត់អត្តសញ្ញាណនៅក្នុងញត្តិនេះ និងញត្តិស្នើសុំលើកទីមួយ គឺសុទ្ធតែអាចទទួលយកបាន និងមានភាពនីយហេតុខ្ពស់។ បន្ថែមលើនេះ កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយ កសចស ទាំងអស់ សុទ្ធតែត្រូវបានបកប្រែភាសារួចហើយ ដូច្នេះវាបានកាត់បន្ថយនូវកង្វល់ដែលពាក់ព័ន្ធនឹងការបែងចែកធនធាននៅក្នុងបញ្ហានេះ។

៦- ចំពោះញត្តិដំណាក់កាលទីមួយ សហព្រះរាជអាជ្ញាស្នើថា កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ត្រូវទទួលយកជាភ័ស្តុតាង ហើយចំណាត់លេខ E3 (ត្រឹមកម្រិតតែចំណាត់លេខនេះមិនទាន់បានដាក់)។ សហព្រះរាជអាជ្ញាស្នើបន្ថែមទៀតឲ្យអង្គជំនុំជម្រះសាលាដំបូងសម្អាងទៅលើភ័ស្តុតាងនេះ ដែលជាប់ជាមួយនឹងសក្ខីកម្មផ្ទាល់មាត់នៅពេលសវនាការ ក្នុងការវាយតម្លៃបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ នៅក្នុងដំណាក់កាលទីមួយនៃសំណុំរឿង០០២នេះ។

៧- សហព្រះរាជអាជ្ញាកំពុងបិតនៅក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណបន្ថែមទៀតលើឯកសារនានាដែលឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ យោងទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញារំពឹងថា ខ្លួននឹងផ្តល់ការកំណត់អត្តសញ្ញាណឯកសារស៊ីសង្វាក់ក្នុងសំណុំរឿងបន្ថែមទៀត ជូនដល់អង្គជំនុំជម្រះ នៅថ្ងៃ ឬនៅមុនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២[9]។

## II. និដ្ឋភាពអំពីឧបសម្ព័ន្ធនានាដែលអមមកជាមួយ

## ក. ឧបសម្ព័ន្ធ I

៨- នៅក្នុង**ឧបសម្ព័ន្ធទី I** ដែលភ្ជាប់ជាមួយនឹងញត្តិបច្ចុប្បន្ននេះ មានសម្រង់អំពីកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត(“OCIJ”) ជាមួយនឹងសាក្សីនានា (“ចម្លើយសាក្សី”)។ សម្រង់ទាំងនេះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[10]។ សម្រង់ទាំងនេះមាន

[9] **E96/7** *ក្នុងឯកសារដដែលដូចខាងលើ,* កថាខណ្ឌទី៣៥.ឃ។

[10] សូមអាន ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ត្រង់កថាខណ្ឌទី២៦២។

ភ័ស្តុតាងមានតម្លៃបញ្ជាក់យ៉ាងស៊ីសង្វាក់គ្នា ទាក់ទងនឹងការបង្ហាញបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើជនជាប់ចោទនៅក្នុងសវនាការលើកដំបូងនៃសំណុំរឿងលេខ០០២ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទសម្លាប់រង្គាល បទធ្វើទុក្ខបុកម្នេញខាងនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ[11]។

៩- នៅក្នុង**ឧបសម្ព័ន្ធទី** I មានសម្រង់ចម្លើយសាក្សីចំនួន៥៨ ដែលបានផ្តល់ជូនដោយសាក្សីចំនួន៥១នាក់ ដោយក្នុងនោះមានសាក្សីចំនួន៧នាក់ បានផ្តល់ចម្លើយចំនួនពីរលើកក្នុងសាក្សីម្នាក់ៗ។ កំណត់ហេតុចំនួន២ដែលបានផ្តល់ដោយសាក្សីម្នាក់ៗក្នុងចំណោមសាក្សីទាំង៧នាក់នេះ បានលើកយោងទៅលើឧប្បត្តិហេតុដូចគ្នាស្តីពីការជម្លៀសដោយបង្ខំ និងដូច្នេះត្រូវបានចាត់ទុកដូចជាចម្លើយតែមួយសម្រាប់ដាក់ជាស្ថិតិនៅក្នុងញត្តិនេះ។ ចម្លើយសាក្សីចំនួន៣ក្នុងចំណោមចម្លើយសាក្សីនៅក្នុង**ឧបសម្ព័ន្ធទី** I ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងបានដាក់លេខ E3 រួចហើយ[12]។

១០- សម្រង់នៅក្នុង**ឧបសម្ព័ន្ធទី** I បានបង្ហាញក្នុងទម្រង់ដូចគ្នា និងយកតាមអភិក្រមដូចគ្នា សម្រាប់ដាក់បញ្ចូលក្នុងសម្រង់នៅក្នុង**ឧបសម្ព័ន្ធទី** I នៃញត្តិស្នើសុំសម្រាប់ដំណាក់កាលទី១ ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៥ ដល់ទី៩ នៃញត្តិនេះ។ ប្រការគួរឲ្យកត់សម្គាល់នោះគឺ នៅក្នុង**ឧបសម្ព័ន្ធទី** I នេះ មិនបានបញ្ចូលសម្រង់ចម្លើយសាក្សី ដែលបានរៀបចំឡើងដោយភាគីទីបីទេ, និងមិនបានបញ្ចូលពីចម្លើយសាក្សីដែលបានផ្តល់សក្ខីកម្មដោយផ្ទាល់មាត់រួចហើយ, ឬមិនបានបញ្ចូលពីសាក្សីនានាដែលត្រូវបានបញ្ជាក់អត្តសញ្ញាណរួចហើយដោយអង្គជំនុំជម្រះសាលាដំបូង ថាជាសាក្សីដ៏មានសក្តានុពលសម្រាប់វគ្គដំបូងនៃសវនាការនេះទេ[13]។ លើសពីនេះ ចំពោះញត្តិស្នើសុំដំណាក់កាលទី១

---

[11] សូមអាន ឯកសារលេខ **E124/7.1** ឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យធ្វើការពិនិត្យពិចារណាឡើងវិញទៅលើវក្យស័ព្ទនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី១៨ តុលា ២០១១ ត្រង់ទំព័រ២ ចំនុច៤។

[12] សូមអាន ឯកសារលេខ D233/3 (E3/414); លេខD278/4 (E3/436); លេខ D234/19 (E3/419)។ សូមអាន ឯកសារលេខ **E185.1** ឧបសម្ព័ន្ធ ក ដែលភ្ជាប់ជាមួយនឹងសេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារនានាដែលបានស្នើសុំឲ្យដាក់ជូនចំពោះមុខអង្គជំនុំជម្រះ, ចុះថ្ងៃទី៩ មេសា ២០១២។

[13] ដូចដែលបានចែងនៅក្នុងឯកសារលេខ **E131/1.1** ឧបសម្ព័ន្ធសម្ងាត់ ក បញ្ជីដោយផ្នែកៗនៃសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការលើកដំបូងក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៥ តុលា ២០១១ និងឯកសារលេខ **E172** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ក្រុមសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីជាបន្ទាប់ ដែលត្រូវធ្វើការស្តាប់ចម្លើយនៅក្នុងសំណុំរឿងលេខ ០០២/០១", ចុះថ្ងៃទី២១ កុម្ភៈ ២០១២។

ចម្លើយសាក្សីដែលត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា ដើម្បីកោះហៅចូលសវនាការ ប៉ុន្តែសាក្សីទាំងនោះមិនទាន់ត្រូវបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង សម្រាប់វគ្គដំបូងនៃសវនាការនៅឡើយទេ[14] ត្រូវបានដាក់បញ្ចូលនៅក្នុង**ឧបសម្ព័ន្ធទី** I រួចហើយ គឺជាសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការដាក់សេចក្តីសន្និដ្ឋាន ដើម្បីឲ្យកោះហៅសាក្សីទាំងនេះ នៅពេលសវនាការនៅក្នុងដំណាក់កាលក្រោយទៀត។

១១- ជាចុងក្រោយ កត់សម្គាល់ឃើញថា ចម្លើយសាក្សីដែលបានដាក់បញ្ចូលនៅក្នុង**ឧបសម្ព័ន្ធទី** I ដែលភ្ជាប់មកជាមួយនឹងញត្តិបច្ចុប្បន្ននេះ គឺមានការជាន់គ្នាក្នុងកំរិតណាមួយ ជាមួយនឹង**ឧបសម្ព័ន្ធទី** I **និងទី** II ដែលភ្ជាប់ជាមួយនឹងញត្តិស្នើសុំសម្រាប់ដំណាក់កាលទី១ ពីព្រោះនៅក្នុងចម្លើយទាំងនេះមានភ័ស្តុតាងពាក់ព័ន្ធនឹងដំណាក់កាលទាំងពីរនៃការជម្លៀសប្រជាជន។ ដើម្បីឲ្យជាក់លាក់នោះគឺមានសម្រង់ចំនួន២៧ក្នុងចំណោមសម្រង់ដែលមាននៅក្នុង**ឧបសម្ព័ន្ធ** I ចំពោះញត្តិបច្ចុប្បន្ននេះ ត្រូវបានយកមកពីចម្លើយសាក្សីដែលបានមកពីសម្រង់ចម្លើយសាក្សីផ្សេងៗទៀត ដែលបានដាក់បញ្ចូលនៅក្នុង**ឧបសម្ព័ន្ធទី** I ឬ ទីII ដែលភ្ជាប់មកជាមួយនឹងញត្តិស្នើសុំសម្រាប់ដំណាក់កាលទីមួយ[15]។

[14] សូមអាន **E9/4** បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជាអាជ្ញា អនុលោមតាមវិធាន៨០ នៃវិធានផ្ទក្នុង រួមបញ្ចូលទាំងឧបសម្ព័ន្ធជាការសម្ងាត់ទី ១, ២, ៣, ៣ក,៤, និងទី៥, ចុះថ្ងៃទី២៨ មករា ២០១១។ សាក្សីទាំងនេះមានចំនួនទាំងអស់១៩ នាក់គឺ - សាក្សី TCCP-1, សាក្សី TCW-63, សាក្សី TCCP-36, សាក្សីTCCP-37, សាក្សី TCW-253, សាក្សី TCW-269, សាក្សី TCW-280, សាក្សី TCW-285, សាក្សី TCCP-45, សាក្សី TCCP-64, សាក្សី TCW-426, សាក្សី TCCP-98, សាក្សី TCW-546, សាក្សី TCW-585, សាក្សី TCCP-138, សាក្សី TCW-661, សាក្សី TCW-674, សាក្សី TCW-718 និង សាក្សី TCCP-169។

[15] សម្រង់ចំនួនដប់ប្រាំបីនៅក្នុងឧបសម្ពន្ធទី I ដែលភ្ជាប់មកជាមួយនឹងញត្តិនេះត្រូវបានយកមកពីចម្លើយសាក្សីនានាដែលត្រូវបានដាក់បញ្ចូលផងដែរ នៅក្នុងឧបសម្ព័ន្ធទី I ដែលភ្ជាប់មកជាមួយនឹងញត្តិស្នើសុំសម្រាប់ដំណាក់កាលទី១នេះ គឺ: ឯកសារលេខ D199/15 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1); ឯកសារលេខ D166/35 (មិនមានរហស្សនាម); ឯកសារលេខ D125/169 (មិនមានរហស្សនាម); ឯកសារលេខ D278/4 [E3/436] (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-36); ឯកសារលេខ D234/19 [E3/419] (សាក្សី TCW-253); ឯកសារលេខ D246/10 (មិនមានរហស្សនាម); ឯកសារលេខ D296/8 (មិនមានរហស្សនាម); ឯកសារលេខD246/3 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-64); ឯកសារលេខD232/88 (សាក្សី TCW-426); ឯកសារលេខD296/10 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-108); ឯកសារលេខ D40/6 (មិនមានរហស្សនាម); ឯកសារលេខ D125/57 (សាក្សី TCW-546); ឯកសារលេខ D278/2 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-138); ឯកសារលេខ D369/31 (មិនមានរហស្សនាម); ឯកសារលេខ D246/16 (មិនមានរហស្សនាម); ឯកសារលេខ D166/9 (សាក្សី TCW-718); ឯកសារលេខ D246/4 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-169); ឯកសារលេខ D296/2 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-172)។ មានសម្រង់ចំនួនប្រាំបួននៅក្នុងឧសម្ព័ន្ធទី I ដែលភ្ជាប់ជាមួយនឹងញត្តិបច្ចុប្បន្ននេះ គឺបានយកមកពីចម្លើយសាក្សីដែលបានដាក់បញ្ចូលផងដែរនៅក្នុងឧបសម្ពន្ធទី II សម្រាប់ដំណាក់កាលដំបូងដែលភ្ជាប់មកជាមួយនិងញត្តិនេះគឺមាន: ឯកសារលេខ D125/47 (សាក្សី TCW-63); D217/2 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-45); ឯកសារលេខ D246/6 (មិនមានរហស្សនាម); ឯកសារលេខ D166/181 (មិនមានរហស្សនាម); ឯកសារលេខ

## ខ. ឧបសម្ព័ន្ធ II - IV

១២- **ឧបសម្ព័ន្ធ II** ផ្តល់ជាទិដ្ឋភាពមួយ ក្នុងទម្រង់ជាតារាងស្តីពីសម្រង់ចម្លើយសាក្សី ដែលមានក្នុង **ឧបសម្ព័ន្ធ I**។ តារាងនេះថែងអំពីទីតាំងនានាដែលប្រជាជនត្រូវបានគេជម្លៀសទៅ និងទីតាំងដែលប្រជាជនត្រូវបានគេជម្លៀសចេញ។ តារាងនេះក៏បានបញ្ជាក់ផងដែរអំពីចំនួននៃការជម្លៀស ដែលសាក្សីនីមួយៗក្នុងចំណោមសាក្សីទាំងនោះបានផ្តល់ចម្លើយ។ **ឧបសម្ព័ន្ធ III** មានបញ្ជីមួយនៃចម្លើយសាក្សីទាំងអស់ដែលត្រូវបានដាក់បញ្ចូលតាមលំដាប់តួអក្សរនៃឈ្មោះសាក្សី និងបញ្ជាក់អំពីចលនាជម្លៀសពាក់ព័ន្ធ ដែលបានយោងនៅក្នុងចម្លើយរបស់សាក្សីទាំងនោះ។

១៣- **ឧបសម្ព័ន្ធ IV** ជាផែនទីមួយដែលបង្ហាញអំពីចលនាជម្លៀសចំនួន ៥៨ ផ្សេងៗពីគ្នា ដែលត្រូវបានកំណត់ដោយសាក្សីចំនួន៤០នាក់។ សាក្សីនានាដែលនៅសល់មិនបានបញ្ជាក់អំពីទីតាំងជាក់លាក់ដែលប្រជាជនត្រូវបានគេជម្លៀសទៅ ឬទីកន្លែងដែលប្រជាជនត្រូវបានជម្លៀសចេញ ឬកំណត់អំពីចលនាជម្លៀសច្រើនដង ដែលគេមិនអាចកំណត់ទីតាំងទាំងនោះបាន។ ក្រុមទាំងពីរប្រភេទនេះមិនអាចត្រូវបានដាក់បញ្ចូលទៅក្នុងផែនទីបានឡើយ។ ដូចដែលបានបង្ហាញនៅក្នុងផែនទី និងបានរៀបរាប់យ៉ាងពិស្តារនៅក្នុងដីកាដំណោះស្រាយ ចលនាជម្លៀសប្រជាជនដ៏សំខាន់ គឺទៅតាមទីតាំងដែល បកក បានកំណត់ ដូចជាទៅភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ) ឬនៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) (ខេត្តកំពង់ធំ និងផ្នែកមួយចំនួននៃខេត្តកំពង់ចាម)។ ស្របពេលជាមួយគ្នានោះដែរ មានការជម្លៀសប្រជាជនទ្រង់ទ្រាយតូចៗចេញពីភូមិភាគបូព៌ា និងនៅក្នុងភូមិភាគបូព៌ានោះតែម្តង (ខេត្តព្រៃវែង និងខេត្តស្វាយរៀង) ឲ្យទៅកាន់ខេត្តក្រចេះ (តំបន់៥០៥), ការជម្លៀសក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ឬមួយក៏ការជម្លៀសនៅក្នុងខេត្តបាត់ដំបង[16]។ ចំពោះញត្តិស្នើសុំសម្រាប់ដំណាក់កាលទីមួយ កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានកំណត់ក្នុង**ឧបសម្ព័ន្ធ I - III** និងបានបង្ហាញនៅលើផែនទី មិនបានឆ្លើយតបទៅនឹងចំនួនចលនាជម្រៀសជាក់ស្តែងនានា ឬទៅនឹងចំនួនមនុស្សពិតប្រាកដដែលត្រូវបានគេជម្លៀសនោះទេ[17]។

D246/11 (ដើមបណ្តឹងរដ្ឋប្បវេណី TCCP-67); ឯកសារលេខD166/50 (មិនមានរហស្សនាម); ឯកសារលេខD217/3 (មិនមានរហស្សនាម); ឯកសារលេខ D166/16 (មិនមានរហស្សនាម); និង ឯកសារលេខ D125/51 (មិនមានរហស្សនាម)។

[16] សូមអាន **D427** ដីកាដំណោះស្រាយ, ត្រង់កថាខណ្ឌទី ២៦២-២៦៣។

[17] ដូចដែលបានចែងនៅក្នុងដីកាដំណោះស្រាយ កសចស ធ្លាប់បានទទួលស្គាល់ពីការពិបាកនៅក្នុងការប៉ាន់ប្រមាណអំពីចំនួនមនុស្សពិតប្រាកដដែលគេបានជម្លៀសនៅក្នុងអំឡុងពេលនោះ។ សូមអាន **D427** ដីកាដំណោះស្រាយ, ត្រង់កថាខណ្ឌទី ២៦៤។

ជាងនេះទៀត វាបានបង្ហាញជាគំរូនៃព្រឹត្តិការណ៍របស់បុគ្គលម្នាក់ៗ ដែលបានរៀបរាប់អំពីកាលៈទេសៈផ្សេងៗគ្នា និងទិសដៅនៃការជម្លៀស។

## III. **ភាពពាក់ព័ន្ធនៃភស្តុតាងដែលមាននៅក្នុងឧបសម្ព័ន្ធ I**

១៤- កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលមាននៅក្នុង**ឧបសម្ព័ន្ធ I** ទាក់ទងដោយផ្ទាល់ទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី ២៦២-២៨២ នៃដីកាដំណោះស្រាយ។ សាក្សីទាំងនោះមានរាប់បញ្ចូលទាំងអ្នកត្រូវបានគេជម្លៀស និងទាំងប្រជាជនធម្មតាដែលជាសាក្សីបានឃើញគេជម្លៀសប្រជាជនដទៃទៀតឲ្យចេញពី ឬផ្លាស់ប្តូរទីតាំងភូមិរបស់ពួកគេ។ ឧបសម្ព័ន្ធនេះរួមមានទាំងអតីតខ្មែរក្រហមដែលមានមុខតំណែងជាក់លាក់ ឬជាយុទ្ធជនធម្មតា។

១៥- កំណត់ហេតុស្តាប់ចម្លើយសាក្សីផ្តល់នូវភស្តុតាងស្តីពីការជម្លៀសដោយបង្ខំ ដែលបានកើតឡើងក្នុងអំឡុងពេលជាង២ឆ្នាំ ជាមួយនឹងការជម្លៀសទ្រង់ទ្រាយធំដែលបានកើតឡើងចាប់ពីភូមិភាគកណ្តាល និងភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)។ បន្ថែមពីលើនេះ នៅមានចម្លើយចំនួន១៤ទៀតដែលបានផ្តល់ភស្តុតាងដ៏សំខាន់អំពីការជម្លៀសជនជាតិចាមឲ្យចេញពីខេត្តកំពង់ចាម ឬនៅក្នុងខេត្តកំពង់ចាមដែលបានកើតឡើង នៅចុងឆ្នាំ១៩៧៥[18]។ ចម្លើយទាំងនេះគឺស្របគ្នាទៅនឹងភស្តុតាងដទៃទៀតដែលត្រូវបានទទួលយកនៅពេលសវនាការ[19] និងបានបង្ហាញពីអត្ថិភាពនៃគោលនយោបាយរបស់ បកក ក្នុងការអនុវត្តការជម្លៀសជនជាតិចាមទ្រង់ទ្រាយធំមួយ ក្នុងគោលបំណងដើម្បីធ្វើឲ្យពួកគេខ្ចាត់ខ្ចាយចេញពីភូមិខ្មែរ ដោយអនុញ្ញាតឲ្យមានតែជនជាតិចាមមួយចំនួនតូចប៉ុណ្ណោះ អាចរស់នៅក្នុងភូមិបាន។

---

[18] សូមអាន D166/29; D125/97.1; D125/73 និង D125/73.1; D125/78.1; D166/161; D125/100 និង D125/100.1; D125/102; D232/88; D125/75; D125/104; D125/99; D125/105; D125/81; D125/101 និង D125/101.1 ។

[19] សូមអាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ **21.3 [E3/154]** ទូរលេខ ១៥ របស់កម្ពុជាប្រជាធិបតេយ្យ ផ្ញើពី ឆុន ជូនបង ប៉ុល, ថ្ងៃទី៣០ វិច្ឆិកា ១៩៧៥ និង **IS 4.25 [E3/1593]** លោក Ben Kiernan, *របប ប៉ុលពត,* ត្រង់លេខERN 00104322-28។

១៦- ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅក្នុង **ឧបសម្ព័ន្ធ I** បានផ្តល់នូវភ័ស្តុតាងមានតម្លៃសម្រាប់ការចោទប្រកាន់ ពីបទឧក្រិដ្ឋនានាប្រឆាំងមនុស្សជាតិ ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជន ដំណាក់កាលទី២ មានដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញខាងនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស តាមរយៈការជម្លៀសដោយបង្ខំ និងតាមរយៈការបាត់ខ្លួនដោយបង្ខំ[20]។ ដោយឡែក កំណត់ហេតុស្តាប់ចម្លើយសាក្សីបានផ្តល់នូវភ័ស្តុតាងស្តីពី៖

(ក) ការផ្លាស់ទីស្ថិតក្នុងលក្ខណៈទ្រង់ទ្រាយធំ - ពាក់ព័ន្ធទៅនឹងការបង្ហាញធាតុផ្សំទូទៅនៃការវាយប្រហារជាប្រព័ន្ធ ឬរាលដាលមួយដោយផ្ទាល់ប្រឆាំងទៅលើប្រជាពលរដ្ឋស៊ីវិល

(ខ) ការផ្លាស់ទីក្នុងលក្ខណៈបង្ខិតបង្ខំរួមទាំងការប្រើកម្លាំង ការគំរាមកំហែង និងការបង្ខិតបង្ខំ ពាក់ព័ន្ធទៅនឹងការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការផ្លាស់ទីដោយបង្ខំ

(គ) ស្ថានភាពអមនុស្សធម៌ក្នុងអំឡុងពេលផ្លាស់ទីដោយបង្ខំ និងនៅពេលធ្វើដំណើរទៅដល់ រួមមាន កង្វះម្ហូបអាហារ ទីស្នាក់អាស្រ័យ ការដឹកជញ្ជូន និងការព្យាបាលផ្នែកវេជ្ជសាស្ត្រជាដើម - ពាក់ព័ន្ធទៅនឹងការបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការសម្លាប់រង្គាល ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស

(ឃ) ការកំណត់គោលដៅទៅលើអ្នកដែលបដិសេធមិនព្រមចាកចេញ និងការបញ្ជូនពួកគេទៅរៀនសូត្រឡើងវិញ ដែលពួកគេមិនដែលបានវិលត្រឡប់មកវិញ - ពាក់ព័ន្ធទៅនឹងការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ

[20] សូមអាន **E124/7.1** ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យពិចារណាឡើងវិញអំពីវាក្យស័ព្ទ ដីកាបំបែកសំណុំរឿង, ថ្ងៃទី១៨ តុលា ២០១១, ត្រង់ទំព័រទី២ ចំណុចទី៥។

(ង) លក្ខណៈអចិន្ត្រៃយ៍នៃការជម្លៀសចេញ ចំពោះអ្នកជម្លៀសត្រូវបង្ខំឱ្យរស់នៅតាមបណ្តាទីតាំងថ្មីៗ ព្រមទាំងចូលរួមក្នុងគម្រោងប្រើប្រាស់ពលកម្មដោយបង្ខំនានា - ពាក់ព័ន្ធទៅនឹងការមិនមានមូលហេតុនានាសម្រាប់ការផ្លាស់ទីប្រជាជន ដែលត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ

(ច) លក្ខណៈជម្លៀសដែលបានគ្រោងទុកជាមុន និងបានរៀបចំយ៉ាងល្អ - ពាក់ព័ន្ធទៅនឹងការមិនមានមូលហេតុណាមួយ សម្រាប់បំលាស់ទីប្រជាជន ដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ និងជាភ័ស្តុតាងបញ្ជាក់ពាក់ព័ន្ធអំពីគោលបំណង, ឧទាហរណ៍៖

- ទាក់ទងនឹងការជម្លៀសទៅភូមិភាគពាយ័ព្យ មានភ័ស្តុតាងស៊ីសង្វាក់គ្នាដែលថាកម្មាភិបាល បកក គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តការជម្លៀសនេះ ចាប់ពីពេលចាប់ផ្តើម រហូតដល់ពេលបញ្ចប់ តាមការប្រើបញ្ជីឈ្មោះ ការរៀបចំការដឹកជញ្ជូន និងការឃ្លាំមើលទៅលើការជម្លៀស នៅគ្រប់ដំណាក់កាលទាំងអស់

- ទាក់ទិននឹងការជម្លៀសដែលកើតឡើងនៅក្រោយការប៉ះបោររបស់ចាម សាក្សីផ្តល់ភ័ស្តុតាងអំពីប្រជាជនចាមត្រូវបានគេបំបែកចេញពីក្រុមធំ នៅមុនការជម្លៀស នៅពេលចាកចេញ និងក្នុងពេលធ្វើដំណើរ ឬពេលទៅដល់។

(ឆ) ការបំបែកជនរងគ្រោះដោយផ្អែកទៅលើចរិតលក្ខណៈបុគ្គល រួមទាំងសមាជិកភាពនៅក្នុងក្រុមជាគោលដៅដូចជា "ប្រជាជនថ្មី" មនុស្សដែលជាប់ទាក់ទងទៅនឹងរបប លន់ នល់ ចាម ចិន និងខ្មែរកម្ពុជាក្រោម - ពាក់ព័ន្ធទៅនឹងការកំណត់ធាតុផ្សំទូទៅ "មូលដ្ឋាននៃការរើសអើង" និងធាតុផ្សំដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើមនុស្សឃាត និងដោយការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

១៧- ជាងនេះទៀត ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលស្វះស្វែងឱ្យមានការទទួលយក នៅក្នុងញ្ញត្តិស្តីពីដំណាក់កាលទី១ បន្ថែមទៅលើការផ្តល់ភ័ស្តុតាងស្តីពីការជម្លៀសប្រជាជនដោយបង្ខំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះផ្តល់ជាភ័ស្តុតាងពាក់ព័ន្ធបញ្ហាក្នុងដំណាក់កាលសវនាការដំបូង និងនៅក្នុងដីកាដំណោះស្រាយ ដូចជា ទិដ្ឋភាពប្រវត្តិសាស្ត្រនយោបាយ និងយោធា ឧក្រិដ្ឋកម្មផ្សេងៗទៀត អត្ថិភាពជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលជាការវាយប្រហារមានលក្ខណៈរាលដាល និងជាប្រព័ន្ធសំដៅទៅលើជនស៊ីវិល និងផលប៉ះពាល់ទៅលើជនរងគ្រោះដែលបណ្តាលមកពីបទល្មើសនោះ និងអំពើផ្សេងៗទៀត។ បញ្ហាបន្ថែមទាំងនេះដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីស្វះស្វែងឱ្យមានការទទួលយកនៅក្នុងញ្ញត្តិនេះ និងញ្ញត្តិស្តីពីដំណាក់កាលទី១ដែលទាក់ទងគ្នា ត្រូវបានកំណត់អត្តសញ្ញាណជាក់លាក់ ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សីម្នាក់ៗដែលមានចែងនៅក្នុង**ឧបសម្ព័ន្ធ ១២** នៃវិធាន ៨០(៣) ស្តីពីបញ្ជីឯកសារសម្រាប់សវនាការ[21] និងបញ្ជីសង្ខេបចម្លើយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលពាក់ព័ន្ធ អនុលោមតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញា[22]។

១៨- អាស្រ័យដោយហេតុផលទាំងឡាយខាងលើ កំណត់ហេតុស្តាប់ចម្លើយសាក្សី គឺអាចទទួលយកបានដោយយោងទៅតាមកត្តានានា ដែលអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណ ហើយដែល *លើសពីអ្វីៗ* គឺមានភវនីយហេតុយ៉ាងខ្ពស់ស្តីពីបញ្ហាផ្សេងៗ ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទីពីរ និងភ័ស្តុតាងផ្សេងៗទៀតដែលបានបញ្ជាក់ខាងលើ។

## IV. ដំណោះស្រាយដែលបានស្នើសុំ

១៩- ក្នុងមូលហេតុដែលបានរៀបរាប់ជាបន្តបន្ទាប់ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូងៈ

[21] ឯកសារ **E9/31** បញ្ជីឯកសារសម្រាប់សវនាការ និងឧបសម្ព័ន្ធពាក់ព័ន្ធ របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៨០ (៣), ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១។

[22] ឯកសារ **E9/13.1** ឧបសម្ព័ន្ធ របស់សហព្រះរាជអាជ្ញាស្តីពីចម្លើយសង្ខេបរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ អនុលោមតាមវិធាន ៨០ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១។

(ក) ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមាននៅក្នុង**ឧបសម្ព័ន្ធ** **I** ជាភ័ស្តុតាង និងចាត់ថ្នាក់ចម្លើយទាំងនោះជាប្រភេទឯកសារ E3 ទៅតាមវិសាលភាពដែលមិនទាន់បានធ្វើ, និង

(ខ) សំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមាននៅក្នុង**ឧបសម្ព័ន្ធ** **I** ជាភ័ស្តុតាងរួម ក្នុងការរួមបញ្ចូលជាមួយសក្ខីកម្មដោយផ្ទាល់មាត់នៅពេលសវនាការ ក្នុងការកំណត់បទចោទប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញារង | | [signature] |